ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាង
# រោងចក្រ ខេមបូ យូនីសួល អិលធីឌី ជាមួយនឹង
# កម្មករនិយោជិតទាំងអស់ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ និងនីតិវិធីពិនូទាត់

ដោយមើលឃើញថារោងចក្រខ្វះការបញ្ជាទិញ ដែលធ្វើអោយរោងចក្រមិនមានការងារអោយកម្មករនិយោជិតធ្វើការងារគ្រប់គ្រាន់ កម្មករនិយោជិតទាំងអស់ ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិក បានឯកភាពគ្នាជាមួយរោងចក្រក្នុងការព្យួរកិច្ចសន្យាការងារ និងក្នុងការទូទាត់ប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

១- **វគ្គទី១** កម្មករនិយោជិតចំនួន ១៥២១នាក់(ស្រីចំនួន១៤១៣នាក់)ក្នុងចំណោមកម្មករនិយោជិតសរុប ១៦៨៦នាក់(ស្រី១៥៤២នាក់)ត្រូវព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃ២២ខែកុម្ភៈឆ្នាំ២០២១រហូតដល់ថ្ងៃទី០១ខែមីនាឆ្នាំ២០២១។សម្រាប់អំឡុងពេលនៃការព្យួរនេះកម្មករនិយោជិតមិនទទួលបានប្រាក់ឈ្នួលទេប៉ុន្តែរោងចក្រនឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួន១០ដុល្លាអាមេរិកដល់កម្មករនិយោជិតម្នាក់ៗដោយផ្តល់ជូនតាមរយៈគណនេយ្យវីង(Wing)របស់កម្មករនិយោជិតដោយរួមជាមួយនឹងប្រាក់ឈ្នួលលើកទី២នៃខែកុម្ភៈរបស់កម្មករនិយោជិតដែលត្រូវផ្តល់ជូននៅចន្លោះថ្ងៃទី ០៥ និងថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២១។

២- រោងចក្រនឹងរៀបចំសំណើរសុំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត និងឯកសារដែលពាក់ព័ន្ធផ្សេងទៀតដើម្បីគោរពជូនទៅក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ដើម្បីទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារក៏ដូចជា ដើម្បីបងប្អូនកម្មករនិយោជិត អាចទទួលបានប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល។

៣- សម្រាប់ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់ឧបត្ថម្ភការធ្វើដំណើរ និងការស្នាក់នៅ និងប្រាក់រង្វាន់ផ្ទាល់ខ្លួនរបស់បងប្អូនកម្មករនិយោជិតសម្រាប់ខែកុម្ភៈ និងខែមីនា ដែលមានការព្យួរកិច្ចសន្យាការងារភាគខ្លះនៃខែនោះ រោងចក្រនឹងផ្តល់ជូនតាមអត្រាសមាមាត្រនឹងចំនួនថ្ងៃដែលបានធ្វើការងារជាក់ស្តែង (ពោលគឺ មិនផ្តល់ជូនចំពោះអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារទេ)។

*(ចន្លោះត្រូវទុកអោយទំនេរ)*

**បញ្ជាក់៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចំពោះកម្មករនិយោជិតទាំងអស់របស់រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹង និយោជកនៃរោងចក្រ ខេមបូ យូនីសូល អិលធីឌី ចាប់ពីពេលចុះហត្ថលេខា នេះតទៅ។

ធ្វើនៅកណ្ដាល ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១

**ថ្នាក់ដឹកនាំសហជីព និងប្រតិភូបុគ្គលិក**

**អគ្គនាយកក្រុមហ៊ុន**

CAMBO UNISOLL LTD.
KINGDOM OF CAMBODIA

CHOI KWANG YEOL